# អ្នកបោះឆ្នោត Minnesota ពាក្យស្នើសុំចុះឈ្មោះបោះឆ្នោត

**ចុះឈ្មោះតាមអនឡាញ mnvotes.org ឬបំពេញពី ជួរទី 1ដល់ទី 8 នៃទម្រង់នេះ។ សូមបោះពុម្ពឱ្យបានច្បាស់។**

**ព័ត៌មានផ្ទាល់ខ្លួន និងលក្ខណ:សម្បត្តិ**

Khmer Voter Registration

election office use only
IP
M
AB

**1.** តើអ្នកជាពលរដ្ឋអាមេរិក បាទ/ចាស់ ☐ ទេ ☐

**2.** តើអ្នកនឹងមានអាយុយ៉ាងតិច18ឆ្នាំនៅ ឬមុនថ្ងៃ បោះឆ្នោតបន្ទាប់ដែរឬទេ? បាទ/ចាស់ ☐ ទេ ☐

ប្រសិនបើអ្នកគូស "ទេ" ទៅលើសំណួរទាំងនេះ ណាមួយ សូមកុំបំពេញទម្រង់នេះ។

**3.** នាមត្រកូល | នាមខ្លួន | នាមកណ្តាល | បច្ច័យ (Jr., Sr., II, III)

**4.** អាសយដ្ឋានរស់នៅរបស់អ្នក (គេហដ្ឋាន) | លេខអគារ | ទីក្រុង | លេខកូដប្រៃសណីយ៍

**5.** ប្រសិនបើមិនអាចផ្ញើសំបុត្រទៅអាសយដ្ឋាន ខាងលើ សូមផ្តល់ប្រអប់សំបុត្រ | ទីក្រុង | លេខកូដប្រៃសណីយ៍

**6.** ថ្ងៃខែឆ្នាំកំណើត (មិនមែនកាលបរិច្ឆេទថ្ងៃនេះ) ________-________- __________ | ស្រុកសាលា (ប្រសិនបើស្គាល់) | ទីក្រុងដែលអ្នករស់នៅ

លេខទូរស័ព្ទ ________-________- __________ | អាសយដ្ឋានអ៊ីមែល

**7.** គូសប្រអប់មួយ និងផ្តល់លេខដែលពាក់ព័ន្ធនឹងអ្នក៖

☐ ខ្ញុំមានប័ណ្ណបើកបរចេញដោយ MN ឬអត្តសញ្ញាណប័ណ្ណ MN លេខ៖ ☐☐☐☐☐☐☐☐☐☐☐☐☐

☐ ខ្ញុំពុំមានប័ណ្ណបើកបរចេញដោយ MN ឬអត្តសញ្ញាណប័ណ្ណ MN ទេ។
លេខបួនខ្ទង់ ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់ខ្ញុំគឺ៖ XXX-XX- ☐☐☐☐

☐ ខ្ញុំពុំមានប័ណ្ណបើកបរចេញដោយ MN អត្តសញ្ញាណប័ណ្ណចេញដោយ MN ឬលេខសន្តិសុខសង្គមទេ។

**ព័ត៌មានចុងក្រោយអំពីការចុះឈ្មោះ -** តើបច្ចុប្បន្នអ្នក ចុះឈ្មោះដោយប្រើឈ្មោះផ្សេង ឬអាយដ្ឋានផ្សេង?

នាមត្រកូលពីមុន | នាមខ្លួនពីមុន | នាមកណ្តាលពីមុន

អាសយដ្ឋានពីមុនដែលអ្នកបានចុះឈ្មោះលើកចុងក្រោយ | ទីក្រុង | រដ្ឋ | លេខកូដប្រៃសណីយ៍

**អាន និងចុះហត្ថលេខាលុះត្រាតែគ្រប់ផ្នែកទាំងអស់ ពាក់ព័ន្ធនឹងអ្នក។**

**8.** ខ្ញុំសូមបញ្ជាក់ថា៖

- ខ្ញុំនឹងមានអាយុយ៉ាងតិច18ឆ្នាំនៅថ្ងៃបោះឆ្នោត។
- គឺជាពលរដ្ឋរបស់សហរដ្ឋអាមេរិក
- នឹងរស់នៅក្នុងរដ្ឋ Minnesota រយៈពេល 20ថ្ងៃមុនថ្ងៃបោះឆ្នោតមកដល់។
- នៅតែស្នាក់នៅនៅអាសយដ្ឋានដែលបានផ្តល់ជូននៅលើទម្រង់ចុះឈ្មោះ។
- មិនស្ថិតក្រោមការឃ្លាំមើលតាមបញ្ជាតុលាកាដែលតុលាការបានបញ្ជាឱ្យលុបចោលសិទ្ធិបោះឆ្នោតរបស់ខ្ញុំ។
- តុលាការពុំរកឃើញថា ខ្ញុំពុំមានសមត្ថភាព ផ្នែកច្បាប់ដើម្បីធ្វើការបោះឆ្នោត
- ប្រសិនបើខ្ញុំត្រូវបានកាត់ឱ្យជាប់ទោស ឧក្រិដ្ឋ ខ្ញុំមានសិទ្ធិបោះឆ្នោត ដោយសារ តែការកាត់ទោសបទឧក្រិដ្ឋនោះអស់សុពលភាព
- (ចប់សព្វគ្រប់) ឬខ្ញុំត្រូវបានទម្លាក់ ចោលការកាត់ទោស។ និង
- បានអាន និងយល់អំពីសេចក្តីថ្លែងនេះថា ការផ្តល់ព័ត៌មានមិនពិតគឺជាបទល្មើស ឧក្រិដ្ឋដែលត្រូវដាក់ទោសមិនលើសពី 5 ឆ្នាំ ឬ ការពិន័យជាទឹកប្រាក់មិនលើសពី $10,000 ឬទាំងពីរ។

**សូមចុះហត្ថលេខាត្រង់នេះ៖ X**________________________ **កាលបរិច្ឆេទ៖** ______-______-**20**______

**Election Judge Official Use Only**

| | ID with Current Name & Address | Photo ID + Document with Current Name & Address | Other |
|---|---|---|---|
| W__________ | ID Number: | Document Type: ____________ | ☐ Vouched For |
| P__________ | | Photo ID Number: ____________ | ☐ Notice of Late Registration |
| SD__________ | ☐ MN Driver's License, Learner's Permit, MN ID Card, or Receipt | ☐ Driver's License, Learner's Permit or State ID Card | ☐ Valid Registration in Same Precinct |
| Initials__________ | ☐ Tribal ID Card | ☐ U.S. Passport ☐ U.S. Military or Veteran ID | ☐ Student ID with College List |
| | | ☐ Tribal ID ☐ Student ID | ID Number: ____________ |

# ទីកន្លែងត្រូវប្រគល់ពាក្យស្នើសុំនេះ

ផ្ញើទៅ ឬទុកទម្រង់នេះនៅ៖

**Secretary of State**
**60 Empire Drive**
**Suite 100**
**St. Paul, MN 55103**

### ព័ត៌មានថ្ងៃផុតកំណត់

យើងលើកទឹកចិត្តអ្នកឱ្យទៅចុះឈ្មោះមុនថ្ងៃបោះឆ្នោត- វានឹងធ្វើឱ្យអ្នកចំណាយពេលតិចនៅកន្លែងបោះឆ្នោត។ ថ្ងៃផុតកំណត់សម្រាប់ចុះឈ្មោះជាមុនគឺរយៈពេល21ថ្ងៃ មុនថ្ងៃបោះឆ្នោត។ បើពុំដូច្នោះទេ អ្នកអាចចុះឈ្មោះ នៅថ្ងៃបោះឆ្នោតនៅទីកន្លែងបោះឆ្នោតរបស់អ្នក។ សូម ចូលមើលវេបសាយត៍ mnvotes.org ដើម្បីដឹងថា តើអ្នកត្រូវយកឯកសារ និង/ឬលិខិតបញ្ជាក់ អត្តសញ្ញាណអ្វីខ្លះទៅជាជាមួយ។

ពាក្យស្នើសុំដែលភាគីទីបីប្រមូលត្រូវទទួលដោយ ការិយាល័យលេខាធិការរដ្ឋ ឬដោយមន្ត្រីបោះឆ្នោតក្រុង របស់អ្នកបោះឆ្នោនៅក្នុងរយៈពេល10ថ្ងៃគិតចាប់ពីថ្ងៃ ដែលអ្នកបោះឆ្នោតបានចុះហត្ថលេខា និងចុះកាលបរិច្ឆេទនៅលើទម្រង់ស្នើសុំ។

### ការផ្តល់ជំនួយ

ពាក្យស្នើសុំប្រភេទធំអាចផ្តល់ជូននៅពេលមានសំណើសុំពីសវនករទីក្រុងរបស់អ្នក ឬ ការិយាល័យលេខា ធិការរដ្ឋ។
ជំនួយពិសេសមានផ្តល់ជូនមនុស្សចាស់ ជនពិការ ឬអ្នកស្ថិតក្នុងអគារថែទាំសុខភាព។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យលេខាធិការរដ្ឋ Minnesota ឬសវនករទីក្រុងរបស់ អ្នក។ ពាក្យស្នើសុំមានជាភាសាផ្សេងៗទៀតនៅក្នុង វេបសាយត៍ mnvotes.org។

### កំណត់សម្គាល់អំពីឯកជនភាព

ថ្ងៃខែឆ្នាំ កំណើតពិតប្រាកដ អាសយដ្ឋានអ៊ីមែលរបស់ អ្នក និងលេខអត្តសញ្ញាណដែលអ្នកផ្តល់ជូន (ប័ណ្ណ បើកបរ Minnesota លេខសម្គាល់រដ្ឋ ឬលេខបួនខ្ទង់ ចុងក្រោយនៃលេខសន្តិសុខសង្គម) នឹងត្រូវរក្សាជា ព័ត៌មានឯកជន។ មានតែមន្ត្រីបោះឆ្នោតប៉ុណ្ណោះដែលអាចចូលមើលព័ត៌មាននេះបាន។

មន្ត្រីបោះឆ្នោតប្រើប្រាស់ថ្ងៃខែឆ្នាំកំណើតពិតប្រាកដ
របស់អ្នកដើម្បីបញ្ជាក់អត្តសញ្ញាណរបស់អ្នកជាមួយនឹងនាយកដ្ឋានសុវត្ថិភាពសាធារណៈ Minnesota ឬ រដ្ឋបាលសន្តិសុខសង្គម។ ប្រសិនបើអ្នកមានលេខ បញ្ជាក់អត្តសញ្ញាណ ប៉ុន្តែអ្នកមិនព្រមផ្តល់ជូន នោះពាក្យស្នើសុំរបស់អ្នកអាចនឹងមិនពេញលេញ ហើយអ្នកអាចនឹងត្រូវដាក់ពាក្យស្នើសុំម្តងទៀត ឬបង្ហាញភ័ស្តុតាងអំពីទីកន្លែង ស្នាក់នៅរបស់អ្នកដើម្បី ឱ្យអ្នកអាចបោះឆ្នោតបាន។

មន្ត្រីបោះឆ្នោតស្នើសុំអ៊ីមែលរបស់អ្នកដើម្បីពួកគេអាច ទាក់ទងទៅអ្នកអំពីពាក្យស្នើសុំរបស់អ្នក។ ជាមួយគ្នា នេះដែរ ការិយាល័យលេខាធិការរដ្ឋអាច អ៊ីមែលទៅអ្នក (ឬទាក់ទងអ្នកតាមមធ្យោបាយផ្សេង ទៀត) អំពីការ បោះឆ្នោត ឬស្នើសុំមតិយោបល់សាធារណៈអំពីការ បោះឆ្នោត។

ទិន្នន័យផ្សេងទៀតនៅលើ ពាក្យស្នើសុំនឹង ត្រូវ បង្ហាញជាសាធារណៈនៅពេល ប្រើប្រាស់សម្រាប់ការ បោះឆ្នោត គោលបំណងនយោបាយ ការអនុវត្តច្បាប់ ឬការជ្រើសរើសគណៈវិនិច្ឆ័យ។ ប្រសិនបើអ្នកចង់ រក្សាព័ត៌មាន ទំនាក់ទំនងរបស់អ្នកជាការសម្ងាត់នៅ ក្រោមហេតុផលបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួន សូមទូរស័ព្ទទៅលេខ 1-877-600-8683។

### ព័ត៌មានបន្ថែមអំពីការបោះឆ្នោត

សម្រាប់ព័ត៌មានបន្ថែមអំពីការបោះឆ្នោត ការចុះឈ្មោះ បោះឆ្នោត ការស្វែងរកទីកន្លែងបោះឆ្នោតរបស់អ្នក លទ្ធផលបោះឆ្នោតប្រចាំរដ្ឋ ព័ត៌មានយុទ្ធនាការ ឬ ការរៀបចំការបោះឆ្នោត សូមចូលទៅកាន់វេបសាយត៍ របស់លេខាធិការរដ្ឋ Minnesota៖ mnvotes.org ឬ ទូរស័ព្ទដោយឥតគិតថ្លៃ 1-877-600-VOTE (1-877-600-8683)។ សម្រាប់ការទាក់ទងតាម TTY/TTD (គថ្លង់ និងអ្នកមានបញ្ហាក្នុងការស្តាប់) សូមទាក់ទង សេវារីឡេ Minnesota 1-800-627-3529 ឬ 711។